ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាល

(សេចក្តីព្រាងលើកទី២)

# ច្បាប់
## ស្តីពី
## សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

************

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងធានា ការពារសិទ្ធិសេរីភាពនិងលើកកម្ពស់ចលនាបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលរបស់ប្រជាពលរដ្ឋខ្មែរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន និងការពារផលប្រយោជន៍សាធារណៈ ព្រមទាំងលើកពង្រឹងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូរវាងសមាគម និង/ឬអង្គការមិនមែនរដ្ឋាភិបាលជាមួយរាជរដ្ឋាភិបាលកម្ពុជា។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់បែបបទទទួលស្គាល់តាមផ្លូវច្បាប់ ដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងកំណត់ទំនាក់ទំនងរវាងសមាគម និង/ឬអង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញាធរសាធារណៈ ដើម្បីអភិវឌ្ឍសង្គមកម្ពុជា។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

វាក្យស័ព្ទដែលប្រើក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ:

- សមាគមក្នុងស្រុក សំដៅដល់ក្រុមរូបវន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរ ដែលបានព្រមព្រៀងគ្នាបង្កើតឡើងដើម្បីគិតគូរពីផលប្រយោជន៍សមាជិក ដោយមិនធ្វើសកម្មភាពណាមួយទាញយកចំណេញមកចែកគ្នា។ សមាគមក្នុងស្រុក អាចធ្វើសកម្មភាពបម្រើផលប្រយោជន៍សាធារណៈបាន។

-អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកសំដៅដល់ក្រុមរូបវ័ន្តបុគ្គល ឬនីតិបុគ្គលសញ្ជាតិខ្មែរដែលបានព្រមព្រៀងគ្នាបង្កើតឡើង ដើម្បីធ្វើសកម្មភាពបម្រើផលប្រយោជន៍សាធារណៈ ដោយមិនធ្វើសកម្មភាពណាមួយទាញយកចំណេញមកចែកគ្នា។

-សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស សំដៅដល់ក្រុមរូបវ័ន្តបុគ្គល ឬនីតិបុគ្គលបរទេសដែលបានព្រមព្រៀងគ្នាបង្កើតឡើងក្រោមច្បាប់បរទេស ដើម្បីគិតគូរពីផលប្រយោជន៍សមាជិក ឬធ្វើសកម្មភាពបម្រើផលប្រយោជន៍សាធារណៈ ដោយមិនធ្វើសកម្មភាពណាមួយទាញយកចំណេញមកចែកគ្នា។

-សមាគម សំដៅដល់សមាគមក្នុងស្រុក និងសមាគមបរទេស។

-អង្គការមិនមែនរដ្ឋាភិបាល សំដៅដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលបរទេស។

-អង្គការសហគមន៍មូលដ្ឋាន សំដៅលើក្រុមប្រជាពលរដ្ឋដែលស្ម័គ្រចិត្តរួមគ្នាបង្កើត គ្រប់គ្រង និងធ្វើសកម្មភាពដោយខ្លួនឯង ដើម្បីបម្រើនិងការពារផលប្រយោជន៍ក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួន។

## ជំពូកទី ២

## ការចុះបញ្ជីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

**មាត្រា ៥.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកអាចបង្កើតឡើងដោយសេរីមិនចាំបាច់មានការអនុញ្ញាត ឬការជូនដំណឹងជាមុនឡើយ ប៉ុន្តែសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទាំងនោះនឹងមិនទទួលបានសមត្ថភាពតាមផ្លូវច្បាប់ទេ លុះត្រាតែខ្លួនបានបំពេញតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៧ នៃច្បាប់នេះ។

អង្គការសហគមន៍មូលដ្ឋាន មិនតម្រូវឱ្យចុះបញ្ជីតាមបទប្បញ្ញត្តិនៃច្បាប់នេះឡើយ លើកលែងតែមានការកំណត់តាមបទប្បញ្ញត្តិនៃច្បាប់ដោយឡែក ប៉ុន្តែអង្គការសហគមន៍មូលដ្ឋានត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីឈ្មោះរបស់អង្គការ វត្ថុបំណង និងឈ្មោះរបស់ប្រធានអង្គការទៅអាជ្ញាធរឃុំ ឬសង្កាត់ដែលខ្លួនធ្វើសកម្មភាព។

**មាត្រា ៦.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ ត្រូវៈ

-មានសមាជិកស្ថាបនិកសញ្ជាតិខ្មែរដែលមានអាយុ១៨ឆ្នាំឡើង ចំនួនយ៉ាងតិច ៣(បី) រូប

-មានទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា

-មានលក្ខន្តិកៈដែលមានខ្លឹមសារស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានាជាធរមាន។ លក្ខន្តិកៈនេះ ត្រូវមានចែងចំណុចសំខាន់ៗដូចខាងក្រោមៈ

-គោលបំណង និងគោលដៅ

-ឈ្មោះជាអក្សរពេញ អក្សរកាត់ ដោយមិនត្រូវចម្លងតាមឈ្មោះជាអក្សរពេញ អក្សរកាត់របស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីមុនរួចហើយ

-សញ្ញាសម្គាល់ មិនត្រូវចម្លងតាមសញ្ញាជាតិ ឬស្ថាប័នរដ្ឋ ឬរូបសញ្ញារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីមុនរួចហើយ ឬរូបសញ្ញាបដិរូបកាកបាទក្រហម ឬអឌ្ឍចន្ទក្រហម ឬស្ថាប័នអន្តរជាតិ

-វិធាននៃការជ្រើសរើស ការបញ្ឈប់ ការបណ្តេញចេញ ការផ្លាស់ប្តូរ ការដកហូតតំណែងប្រធាន ឬតំណែងនាយកប្រតិបត្តិ

-វិធាននៃការប្តូរឈ្មោះ ឬការប្តូរសញ្ញាសម្គាល់ ឬការធ្វើវិសោធនកម្មលក្ខន្តិកៈ

-ប្រភពធនធាន និងទ្រព្យសម្បត្តិ

-វិធាននៃការគ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិ

-វិធាននៃការរំលាយ និងវិធាននៃការចាត់ចែងធនធាន និងទ្រព្យសម្បត្តិនៅពេលត្រូវបានរំលាយ។

**មាត្រា ៧.-**

ដើម្បីចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ប្រធានសមាគម ឬប្រធានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវបំពេញសំណុំលិខិតដូចខាងក្រោមៈ

-ពាក្យសុំចុះបញ្ជី ចំនួន២(ពីរ)ច្បាប់

-លិខិតបញ្ជាក់អាសយដ្ឋាន នៃទីស្នាក់ការកណ្តាលរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកពីមេឃុំ ឬចៅសង្កាត់ ចំនួន ១(មួយ)ច្បាប់

-លក្ខន្តិកៈចុះហត្ថលេខាដោយប្រធានសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ចំនួន ២(ពីរ)ច្បាប់

-ប្រវត្តិរូបសង្ខេបរបស់ស្ថាបនិកម្នាក់ៗដោយមានបិទរូបថតបច្ចុប្បន្នទំហំ ៤ គុណនឹង ៦ ចំនួន ២(ពីរ)ច្បាប់។

មាត្រា ៨.-

ក្រសួងមហាផ្ទៃត្រូវពិនិត្យសំណុំលិខិត និងនីត្យានុកូលភាពនៃលក្ខន្តិកៈរបស់សមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ហើយត្រូវសម្រេចព្រមទទួល ឬមិនព្រមទទួលចុះបញ្ជីរយៈពេលយ៉ាងយូរ ៤៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ។

ក្រសួងមហាផ្ទៃ ត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលក្រសួងមហាផ្ទៃមិនព្រមទទួលចុះបញ្ជី ដោយឱ្យធ្វើការកែតម្រូវរយៈពេលយ៉ាងយូរ ៤៥(សែសិបប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងករណីពិនិត្យឃើញថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក បានកែតម្រូវចំណុចខ្វះខាតរួចហើយ ក្រសួងមហាផ្ទៃត្រូវចុះបញ្ជីរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីថ្ងៃបានទទួលសំណុំលិខិតកែតម្រូវ។

ក្នុងករណី ក្រសួងមហាផ្ទៃ សម្រេចមិនព្រមទទួលចុះបញ្ជី សាមីសមាគមឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានសិទ្ធិប្ដឹងតវ៉ាទៅតុលាការ។

មាត្រា ៩.-

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនឹងក្លាយជានីតិបុគ្គលមិនយកចំណេញ ឬជានីតិបុគ្គលបម្រើផលប្រយោជន៍សាធារណៈ ចាប់ពីថ្ងៃដែលក្រសួងមហាផ្ទៃបានចុះបញ្ជី។

មាត្រា ១០.-

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការធ្វើវិសោធនកម្មលក្ខន្តិកៈ ឬការផ្លាស់ប្ដូរទីស្នាក់ការឬការផ្លាស់ប្ដូរតំណែងប្រធាន ឬតំណែងនាយកប្រតិបត្តិ ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដែលបានផ្លាស់ប្ដូរ។

## ជំពូកទី ៣

## សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស

មាត្រា ១១.-

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានបំណងធ្វើសកម្មភាពក្នុងព្រះរាជាណាចក្រកម្ពុជា រយៈពេលលើសពី ១(មួយ)ឆ្នាំ ត្រូវចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលធ្វើសកម្មភាពរយៈពេលតិចជាង១(មួយ)ឆ្នាំ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរពីគម្រោងជំនួយពេលវេលា និងទីកន្លែងអនុវត្តទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា ១២.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមានបំណងអនុវត្តគម្រោងជំនួយនានានៅក្នុងព្រះរាជាណាចក្រកម្ពុជារយៈពេលលើសពី ១(មួយ)ឆ្នាំ ត្រូវដាក់ពាក្យសុំចុះអនុស្សរណៈនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយបំពេញលក្ខខ័ណ្ឌ និងភ្ជាប់មកជាមួយនូវសំណុំលិខិតដូចខាងក្រោម :

- លិខិតរបស់ប្រធានសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានទីស្នាក់ការអចិន្ត្រៃយ៍របស់ខ្លួននៅបរទេស ស្នើតែងតាំងតំណាងរបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវ ប្រវត្តិរូបសង្ខេបរបស់បុគ្គលដែលស្នើតែងតាំងចំនួន ១(មួយ)ច្បាប់ និងស្នើសុំបើកទីស្នាក់ការតំណាងចំនួន ១(មួយ)ច្បាប់
- លិខិតបញ្ជាក់អាសយដ្ឋាន នៃទីស្នាក់ការតំណាងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ពីមេឃុំ ឬចៅសង្កាត់ចំនួន ១(មួយ)ច្បាប់
- លិខិតចេញដោយអាជ្ញាធរមានសមត្ថកិច្ចប្រទេសដើមអនុញ្ញាតឱ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដំណើរការចំនួន ១(មួយ)ច្បាប់
- លិខិតគាំទ្រគម្រោងជំនួយនានារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសចេញដោយក្រសួង ឬស្ថាប័នរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាចំនួន១(មួយ)ច្បាប់
- លិខិតបញ្ជាក់ពីចំនួនថវិកាសម្រាប់អនុវត្តគម្រោងជំនួយនានារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសរយៈពេលយ៉ាងតិច ១(មួយ)ឆ្នាំ បញ្ជាក់ដោយទីស្នាក់ការអចិន្ត្រៃយ៍របស់ខ្លួននៅបរទេសចំនួន ១(មួយ)ច្បាប់។

ប្រធានសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវធានាថា នឹងប្រគល់លិខិតប្រកាសគណនីធនាគាររបស់ខ្លួន ដែលបានផ្ញើនៅធនាគារណាមួយទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជាចំនួន ១(មួយ)ច្បាប់ យ៉ាងយូរ ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានចុះអនុស្សរណៈ។ ក្នុងករណី មិនបានផ្តល់តាមកាលកំណត់ខាងលើដោយគ្មានមូលហេតុសមស្រប ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបអនុស្សរណៈរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសនោះចោលវិញ។

**មាត្រា ១៣.-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យខ្លឹមសារនៃសំណុំលិខិត ហើយត្រូវសម្រេចយល់ព្រម ឬមិនយល់ព្រមចុះអនុស្សរណៈជាមួយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល

បរទេស យ៉ាងយូរ ៤៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ។

**មាត្រា ១៤.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវធ្វើការពិភាក្សាឯកភាពជាមួយក្រសួង ឬស្ថាប័នរបស់រាជរដ្ឋាភិបាលដែលជាដៃគូលើគម្រោងជំនួយនានា មុននឹងដាក់ពាក្យសុំចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចមានចែងក្នុងចំណុចទី៤ មាត្រា១២ នៃច្បាប់នេះ។ ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសណាដែលគ្មានដៃគូជាមួយក្រសួង ឬស្ថាប័នតាមវិស័យណាមួយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសនោះអាចពិភាក្សា និងចុះអនុស្សរណៈដោយផ្ទាល់ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា ១៥.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវមានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងជំនួយនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយធានាថា ប្រាក់ចំណាយបុព្វហេតុរដ្ឋបាល រួមមានបៀវត្សរបស់បុគ្គលិក សម្ភារៈការិយាល័យ និងការចំណាយសម្រាប់ដំណើរការការងារក្នុងការិយា-ល័យ មិនឱ្យលើសពី២៥(ម្ភៃប្រាំ)ភាគរយនៃថវិកាសរុប។

**មាត្រា ១៦.-**

បន្ទាប់ពីចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រួចហើយ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវប្រកាសកិច្ចព្រមព្រៀងលើគម្រោងជំនួយរបស់ខ្លួននៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

**មាត្រា ១៧.-**

អនុស្សរណៈមានសុពលភាពរយៈពេលយ៉ាងយូរ ៣(បី)ឆ្នាំ ទៅតាមគម្រោងជំនួយនានារបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស។សុពលភាពអនុស្សរណៈនឹងត្រូវបញ្ចប់ជាស្វ័យប្រវត្តិក្រោយថ្ងៃផុតកំណត់។

ក្នុងករណី សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានបំណងបន្តសុពលភាពអនុស្សរណៈ ត្រូវដាក់លិខិតស្នើសុំបន្តសុពលភាពអនុស្សរណៈឱ្យបាន ៩០(កៅសិប)ថ្ងៃ មុនថ្ងៃផុតសុពលភាពអនុស្សរណៈ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាចបញ្ចប់សុពលភាពអនុស្សរណៈ ដូចមានចែងក្នុងកថាខ័ណ្ឌទី១ ខាងលើ ក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសធ្វើសកម្មភាពប៉ះពាល់ដល់សន្តិភាព ស្ថេរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កនូវភាពអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់របស់សង្គមជាតិកម្ពុជា។

**មាត្រា ១៨.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងករណីមានការផ្លាស់ប្តូរទីស្នាក់ការតំណាង ឬតំណាងប្រចាំប្រទេស ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដែលបានផ្លាស់ប្តូរ។

## ជំពូកទី ៤

## ធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល

**មាត្រា ១៩.-**

ធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមានដូចខាងក្រោម:

-ភាគទាន ឬវិភាគទាន ឬបរិវិសទានរបស់សមាជិក

-ធនធាន និងទ្រព្យសម្បត្តិផ្ទាល់របស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

-អំណោយស្របច្បាប់ពីរូបវន្តបុគ្គល ឬនីតិបុគ្គល

-ចំណូលពីប្រភពស្របច្បាប់ផ្សេងៗទៀត។

**មាត្រា ២០.-**

ធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស បានមកពីប្រភពស្របច្បាប់នានា។

## ជំពូកទី ៥

## សិទ្ធិ ផលប្រយោជន៍ និងភារកិច្ចរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល

**មាត្រា ២១.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬចុះអនុស្សរណៈ អាចស្នើសុំនាំចូលសម្ភារៈគ្រឿងបរិក្ខារចាំបាច់សម្រាប់ប្រើប្រាស់ស្របតាមគម្រោងជំនួយរបស់ខ្លួន ដោយពន្ធ និងអាករលើការនាំចូលជាបន្ទុករបស់រដ្ឋ។

**មាត្រា ២២.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬចុះអនុស្សរណៈមានសិទ្ធិចុះកិច្ចសន្យា សហប្រតិបត្តិការជាមួយដៃគូក្នុងការអនុវត្តនីគម្រោងសកម្មភាពស្របតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២៣.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬចុះអនុស្សរណៈ មានសិទ្ធិជ្រើស

ជ្រើសបុគ្គលិក ឬកម្មករខ្មែរដើម្បីបម្រើការងារ។ ការជ្រើសរើសនេះ ត្រូវអនុវត្តតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងត្រូវជ្រើសរើសបុគ្គលិក ឬកម្មករខ្មែរឱ្យបានច្រើនជាអតិបរមា។

**មាត្រា ២៤.-**

ទីស្នាក់ការតំណាងរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស បុគ្គលិកបរទេស និងបុគ្គលិកខ្មែរ រួមទាំងសមាជិកក្រុមគ្រួសាររបស់ខ្លួន ពុំទទួលបានអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិជាអ្នកការទូត ដូចមានចែងក្នុងអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦៣ ស្តីពីទំនាក់ទំនងការទូតឡើយទាក់ទងនឹងសកម្មភាពបំពេញមុខងាររបស់ខ្លួន និងរឿងក្តីគ្រប់ប្រភេទ លើកលែងតែមានកិច្ចព្រមព្រៀងពិសេសរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស។

**មាត្រា ២៥.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ត្រូវផ្ញើរបាយការណ៍ស្តីពីសកម្មភាព និងស្ថានភាពថវិកាប្រចាំឆ្នាំច្បាប់ចម្លង ទៅក្រសួងមហាផ្ទៃមិនឱ្យហួសពីដំណាច់ខែកុម្ភៈ។ របាយការណ៍នេះត្រូវតម្កល់ទុកនៅទីស្នាក់ការរបស់ខ្លួន រយៈពេលយ៉ាងតិច ៥ (ប្រាំ)ឆ្នាំ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សរណៈត្រូវផ្ញើរបាយការណ៍ស្តីពីសកម្មភាព និងស្ថានភាពថវិកាប្រចាំឆ្នាំ ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រយៈពេលយ៉ាងយូរ ២(ពីរ)ខែ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធរបស់ខ្លួន។

## **ជំពូកទី ៦**

## **ការផ្អាកសកម្មភាព ការរំលាយ ការបញ្ចប់សុពលភាពអនុស្សរណៈ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល**

**មាត្រា ២៦.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អាចផ្អាកសកម្មភាព ឬរំលាយបានតាមការកំណត់ក្នុងលក្ខន្តិកៈរបស់ខ្លួន ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ។

**មាត្រា ២៧.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស អាចសុំផ្អាកសកម្មភាព ឬសុំបញ្ចប់សុពលភាពអនុស្សរណៈបាន ដោយត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងចម្លងជូនស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។

**មាត្រា ២៨.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានរំលាយដោយខ្លួនឯងដូចមាន

ចែងក្នុងមាត្រា២៦ នៃច្បាប់នេះ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ ត្រូវអនុវត្តតាមលក្ខន្តិកៈ ឬសេចក្តីសម្រេចរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ។

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលត្រូវបានរំលាយតាមសេចក្តីសម្រេចរបស់តុលាការ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ ត្រូវអនុវត្តតាមសេចក្តីសម្រេចនោះ។

**មាត្រា ២៩.-**

សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលត្រូវបានបញ្ចប់សុពលភាពអនុស្សរណៈដូចមានចែងក្នុងមាត្រា២៧ នៃច្បាប់នេះ ការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានស្នើសុំបើកទីស្នាក់ការតំណាងនៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៧
## វិធានការរដ្ឋបាល

**មាត្រា ៣០.-**

ក្នុងករណីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលមិនបានអនុវត្តតាមមាត្រា១០ ឬកថាខ័ណ្ឌទី១ មាត្រា២៥ នៃច្បាប់នេះ ក្រសួងមហាផ្ទៃ ត្រូវរំលឹកជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ១(មួយ)ខែ។ ក្នុងករណីមិនអនុវត្ត ក្រសួងមហាផ្ទៃ ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយទុករយៈពេលយ៉ាងយូរ ៣(បី)ខែ។ ក្នុងករណីនៅតែមិនព្រមអនុវត្តតាមការព្រមាន ក្រសួងមហាផ្ទៃត្រូវសម្រេចជាលាយលក្ខណ៍អក្សរលុបឈ្មោះចេញពីបញ្ជី។

**មាត្រា ៣១.-**

ក្នុងករណីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលការបរទេសដែលមិនបានអនុវត្តតាមមាត្រា១៨ ឬកថាខ័ណ្ឌទី២ មាត្រា២៥ នៃច្បាប់នេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវរំលឹកជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ១(មួយ)ខែ។ ក្នុងករណីមិនអនុវត្ត ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវព្រមានជាលាយលក្ខណ៍អក្សរដោយទុករយៈពេលយ៉ាងយូរ ៣(បី)ខែ។ ក្នុងករណីនៅតែមិនព្រមអនុវត្តតាមការព្រមាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវសម្រេចជាលាយលក្ខណ៍អក្សរបញ្ចប់សុពលភាពអនុស្សរណៈ។

## ជំពូកទី ៨
## អន្តរប្បញ្ញត្តិ

**មាត្រា ៣២.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបាន

គម្គល់សំណុំលិខិតនៅក្រសួងមហាផ្ទៃ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ស្តីពីការបន្តសកម្មភាពរបស់ខ្លួន យ៉ាងយូរ ៣៦៥ (បីរយហុកសិបប្រាំ)ថ្ងៃ ដោយមានបញ្ជាក់អំពីឈ្មោះ អាសយដ្ឋាននៃទីស្នាក់ការ អត្តសញ្ញាណថ្នាក់ដឹកនាំ និងលក្ខន្តិកៈកែប្រែចុងក្រោយ(បើមាន)។ បើហួសរយៈពេលដូចបានកំណត់ខាងលើនេះ ក្រសួងមហាផ្ទៃចាត់ទុកថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះបានបោះបង់សកម្មភាពរបស់ខ្លួនហើយ។

**មាត្រា ៣៣.-**

បន្ទាប់ពីច្បាប់នេះចូលជាធរមាន សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរួចហើយ នៅមានសុពលភាពអនុវត្តរហូតដល់ថ្ងៃផុតកំណត់សុពលភាពអនុស្សរណៈ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ៣៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័ត
នៅថ្ងៃទី....ខែ......ឆ្នាំ២០១..នាសម័យប្រជុំរដ្ឋសភាលើកទី....
នីតិកាលទី៤ ។

រាជធានីភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ២០១..

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី បណ្ឌិត ហេង សំរិន**